# ស្តេច អង្គរ

# ប្រលោមលោក

## និពន្ធ ដោយ លោក ផល ម៉ាកាលី

ជា ជនជាតិ បារាំងសែស

បកប្រែ ពី ភាសា បារាំង មក ខ្មែរ ដោយ

ឧប សៅ សទ្ធា



# ស្ដេច អន្ធរ

## ប្រលោមលោក

មាតិការឿង


អារម្ភកថា ........................................ 3

ការផ្ដើម ........................................ 4

ក្បួន ដង្ហែ ........................................ 4

ភាគ ទី១ ........................................ 14

ស្ដេច តសី ........................................ 14

ភាគ ទី២ ........................................ 28



និពន្ធ ដោយ ផល ម៉ាកាលី

បកប្រែ ដោយ ឱប សៅ សុទ្ធា

# ស្តេច អង្គរ

ប្រលោមលោក

## អារម្ភកថា

ការ សរសេរ នេះ គឺ ជា ការ សាកល្បង បកប្រែ ពី សៀវភៅ ប្រលោមលោក ជា ភាសា បារាំង មាន ចំណងជើង ថា « Le Roi d'Angkor » (ស្តេច អង្គរ) សរសេរ ដោយ អ្នក និពន្ធ បារាំង សែស ម្នាក់ ប្រើ នាម និពន្ធ របស់ លោក ជា ឈ្មោះ ខ្មែរ ថា ផល ម៉ាកាលី (PHÃL Makhli)។ សៀវភៅ នេះ បាន បោះ ពុម្ព ផ្សាយ នៅ ឆ្នាំ ១៩៥២[1]។ អ្នក និពន្ធ សរសេរ បង្ហាញ នៅ ក្នុង ចិត្ត គំនិត របស់ លោក អំពី ប្រពៃណី បុរាណ នៃ រាជានិយម ខ្មែរ មួយ ចំនួន ហើយ តួអង្គ ទាំង ឡាយ នៅ ក្នុង ស្នាដៃ នេះ គឺ សុទ្ធ ជា ការ ប្រឌិត របស់ លោក គួរ ឱ្យ ចាប់ អារម្មណ៍ ដែល ទាក់ ទាញ ចិត្ត ខ្ញុំ ឱ្យ យក មក បក ប្រែ ជា ភាសា ជាតិ ខ្មែរ។

សៀវភៅ នេះ មាន ១៩ ភាគ បូក និង ការផ្តើម។ សព្វ ថ្ងៃ ខ្ញុំ កំពុង បក ប្រែ បន្ត បន្ទាប់ គ្នា ហើយ នឹង ចុះ ផ្សាយ បន្ត បន្ទាប់ គ្នា ដែរ ដោយ មិន កំណត់ ពេល វេលា ផ្សាយ ទៀង ទាត់ នោះ ឡើយ។

ថ្ងៃ ទី ២៨ វិច្ឆិកា ឆ្នាំ ២០១៩

ឧប សៅ សង្ហា

---

[1] Editions Albin Michel.

# ស្តេច អន្តរ

**ប្រលោមលោក**

# ការផ្តើម

## ក្បួន ដង្ហែ

ពួក ព្រាហ្មណ៍ នាំ គ្នា ធ្វើ ដំណើរ ចូល ព្រៃស្បាត ជា ក្បួន ដង្ហែ ដើម្បី ទៅ យាង ព្រះ រាជ យុវ័ន មាន សម្បុរ ស្លេកស្លាំង ហើយ នាំ គ្នា ផ្លាស់ ចីពរ ចាស់ ពណ៌ លឿង របស់ ព្រះអង្គ ប្តូរ នឹង ភូសា[2] បញ្ជា នៃ ពួក យាចក នាំ គ្នា យាង ព្រះអង្គ ឱ្យ គង់ លើ ដំរី ពិសិដ្ឋ ដោយ មិន រវល់ យក ពេល វេលា សំរាប់ បំពាក់ ព្រះសង្វារ លើ ភូសា ជា មុន។ ពួក អ្នក បូជាចារ្យ[3] ទាំង នោះ ញ័រ ដៃ ដោយ មាន សេចក្តី រីករាយ និង ប្រណិប័តន៍ ដ្បិត មាន អារម្មណ៍ ថា ប្រជួប ព្រះ រាជ យុវ័ន នៅ ក្នុង ព្រៃស្បាត មាន ដើម ម៉ៃសាក់ នោះ ជា ការ ប្រទះ ដ៏ ល្អ ហើយ ពួក ព្រាហ្មណ៍ ក៏ នាំ គ្នា ជឿ ផង ដែរ ថា ជា លាភជ័យ សំរាប់ សេចក្តី ថ្កុំថ្កើង នៃ ប្រទេស កម្ពុជា។ ព្រះ ចៅ ថ្មី ជា កុមា ព្រះអង្គ មាន អារម្មណ៍ ក្នុង ចិត្ត ថា ខ្លួន អញ មាន ទ្រង់ទ្រាយ ចម្លែក ជា តុក្កតា រុំ ព័ន្ធ ដោយ ខ្សែឆ្នារ ប្រៀប ប្រដូច ជា ដើមឈើ រុំ ព័ន្ធ ដោយ វល្លិ៍។ ប៉ុន្តែ ព្រះអង្គ ទ្រង់ គ្មាន ពេល វេលា នឹង បារម្ភ អំពី កំណើត នៃ ព្រះ ចេស្តា របស់ ទ្រង់ តាម ទស្សនីយភាព នៃ វិការ នូវ ភាវរូប របស់ ទ្រង់ ដែល មិន អាច គិត ស្មាន បាន : ពួក ព្រាហ្មណ៍ ក៏ នាំ គ្នា ពោល ជា

---

[2] ភូសា : សំលៀកបំបាក់ ប្រើ ជា រាជ វាក្យសព្ទ។
[3] អ្នក បូជាចារ្យ : sacrificateur.

# ស្តេច អន្ធរ

## ប្រលោមលោក

លើក ទី២ បញ្ហា ឱ្យ ដំរី ស លត់ជង្គង់ ព្រោះ ដល់ វេន ពួក ខ្លួន ទទួល ថ្វាយ បង្គំ ទេព្តា ជា នរណា ? ព្រះ ស្វាមី ជីវិន របស់ ព្រះ ទេវី ព្រះ នាម កាលី និង  ព្រះ អគ្គមហេសី ដ៏ តូច ច្រឡឹង ដែល ជា កុមារី មាន អាយុ ប្រាំពីរ វស្សា ដែល ត្រូវ បាន គេ ទើប នឹង ធ្វើ ពិធី លើកស្លា ជា មួយ នឹង ព្រះរាជ យុវ័ន។ ក្សិយនោះ គ្រប់ ដើមឈើ ទាំងឡាយ ក៏ នាំ គ្នា ច្រហាប ស្លឹក របស់ ខ្លួន ដើម្បី ទុក ឱ្យ សម្រែក នៃ នរូ ទាំង ឡាយ មាន វិភាព (សម្រស់) ដូច រាជសីហ៍ ឆ្លង កាត់ បាន :

- សិរី រុងរឿង ដល់ ព្រះបាទ ព្លសាណវ័ន្ទ !
- សិរី រុងរឿង ដល់ ព្រះបាទ ព្លសាណវ័ន្ទ ! ស្រែក ជា ភាសា សំស្ក្រឹត ដូច ជា សម្រែក របស់ រាជសីហ៍ បី ពាន់ ជា បព្វជិត ដែល បង្កើន ចំនួន បី រយ លាន នាក់ ជា មនុស្ស ប្រុស ស្រី ជា ទេវតា ជា ម្រឹក ជា ផ្កាយ រស់នៅ ក្នុង រាជ នគរ លើ សមុទ្រ ដើម្បី ព្រះ រាជ យុវ័ន។ វា ហាក់ បី ដូច ជា អាណាចក្រ របស់ ព្រះអង្គ ធ្វើ ដំណើរ មក រក ព្រះអង្គ លើ ផ្កា កេសរកូល និង ផ្កា ចន្ទ ដែល ផ្កាច់ ខ្លួន ឯង ចេញ ពី ភាព ផ្អែម ល្ហែម នៃ ព្រៃស្បាត ដែល បាន ធ្វើ សច្ចាធិដ្ឋាន សុំ ឱ្យ ព្រះ អង្គ ក្លាយ ជា ព្រះ លោះបាប នៅ លើ ពិភពលោក នេះ។
- អៃយ៉ា ! នៅ លើ បល្ល័ង្ក មាស លើ ខ្នង ដំរី ស ឃើញ ព្រះអង្គ ដូច យាចក ចេះ ឈរ ជា រាជ ឥរិយាបថ បញ្ឈរ នៅ នឹង ថ្កល់ ដូច គ្នា នឹង ព្រះ វាសុរា (រាត្រី) ជា គូដណ្តឹង យក

# ស្ដេច អង្គរ

## ប្រលោមលោក

តម្រាប់ តាម ព្រះ ស្វាមី, និង ទេព្តា ជា នរណា ? ដែល ជា មិត្ត ពី យុវ័នភាព  ដែល ធ្លាប់ តែ ធ្វើ តាម អីចឹង។ ក្សីយនោះ  បើ  ទោះបី  ជា  ប្រជានុរាស្ត្រ  ប្រញាប់  ដើរ  កាត់ ព្រឹក្សា ក្នុង ដង្ហើម សុវណ្ណ និង ទេវ ក្លិន ជា ជួរ ក្នុង ក្បួន ដង្ហែ  តែ ជា ក្បួន សំរាប់ ស្តេច អង្គរ បង្ហាញ ឱ្យ នរូ ឃើញ ព្រះអង្គ លើ ព្រះ ទីនាំង សាមញ្ញ។ ក្បួន ដង្ហែ ជា រីត៏ នោះ ហៅ ថា « ក្បួន ដង្ហែ តូច នៃ ការ បង្ហាញ ខ្លួន » រៀបចំ ជា លំនាំ ល្អ ជុំវិញ ដំរី ពិសិដ្ឋ និង, គ្មាន បាត់ មួយ ចំណែក តូច  សោះ  នូវ  ភាព  ឧឡារិក  និង  អ៊ឹងអធិក  របស់  រាជ ក្បួន ដង្ហែ ដែល កំដរ ដោយ សម្លេង គង ឃ្មោះ ស្គរ ចាប៉ី ត្រែ និង ពិណ ដែល ធ្វើ ដំណើរ នៅ ចំពោះ ទីកមុខ សញ្ជឹង គិត នៃ ព្រឹក្សា, រី ឯ ក្រពើ បញ្ចេញ មាត់ ពី ក្នុង ទឹក, ស្វា ស្លិត  នៅ  ស្ងៀម  លើ  មែកឈើ,  ក្តាន់  ល្វើយ  សំរាក  នៅ ក្រោម ឆាយា នៃ កេសា   ល្ដេន[4] យោនយាន ពី មែក នៃ ដើម  ពោធិ  ដែល  បែក  សាខា  យ៉ាង  ល្អ  ប្រពៃ  ហើយ  អ្វី ដែល  នាំ  ឱ្យ  មាន  ការ  ភ្ញាក់ផ្អើល  គឺ  នៅ  ទី  នោះ  ឃើញ មាន សត្វ ខ្លា រមាស ខ្លារខិន ខ្ទីង ដំរី ព្រៃ និង គ្រប់ ស្តេច ម្រឹគ ទាំងឡាយ នាំ គ្នា មក អង្គុយ ឬ ដេក ស្រប៉ាប លើ កំរាល ស្មៅ ប្រកប ដោយ សេចក្តី ស្ងាត់ ស្ងៀម ដើម្បី រង់ចាំ មើល ព្រះ ចេស្តា ដែល ជា ទេវតា។

---

4 ល្ដេន : ធ្លាក់ ចុះ។

# ស្តេច អន្ធរ

## ប្រលោមលោក

ម្រឹក ទាំង នោះ តាម ចន្លោះ របារ នៃ លតា (វល្លិ៍) មើល ឃើញ ក្បួន ដង្ហែ រាជីនី (សេះ) ដែល ពួក អ្នក ជិះ ជា កុមារា មាន ថ្ពាល់ វង់មូល ស្លៀក សំលៀកបំពាក់ ពណ៌ ស វា ហាក់ បី ដូច ជា សារជាតិ នៃ រាជាធិបតេយ្យ ត្រូវ មាន ប្រភព ចេញ ពី ករុណា, ធាតុ បរិសុទ្ធ របស់ យុវ័ន ទាំង នោះ។

តែ បន្តិច ក្រោយ មក ចក្ខុវិស័យ នៃ ភាព បរិសុទ្ធ នោះ វា រលាយ ទៅ ក្នុង ភាព ឧត្តម និង កម្លាំងទេព នៅ ពេល នោះ។ អភិមានៈ នៃ រុក្ខជាតិ ក៏ លំឱន ចិត្ត លំអុត[5] នៅ ក្រោម វជិរៈ (រន្ទះ) នៃ ហយានីក[6] ភូមិន្ទ ដែល បង្ហាញ នូវ មោទនភាព នៃ ហយៈ (សេះ) សម្បុរ ខ្មៅ ថ្លា បំពាក់ បង្ងៀរ ពណ៌ មាស ជិះ ដោយ ពួក ហាយិន ជា យោធិន លើ បន្ទុះ ភ្លុក ដែល នាំ ឱ្យ ខ្លា ទាំងឡាយ ចោល ភ្នែក មើល នរៈ ទាំងនោះ។

ដំរី ព្រៃ នៅ ពេល បាន ឃើញ ដំរី អង្គរ, ចំនួន ម្រយ ជិះ ដោយ ពួក ទេព្តា និង ទេពារក្ស លើ បល្ល័ង្ក, យាត្រា បន្ទាប់ ពី ក្បួន ដង្ហែ ពួក ក្សត្រិយៈ ក៏ មិន នាំ គ្នា ស្រែក ? តែ ពី ក្រោយ របារ នៃ លតា ពួក កូន ដំរី បុរាណ វិលាប ជា ស ម្លេង តិចៗ : ថា « អ្ហូះ រៀមច្បង រៀមច្បង ទាំងឡាយ, ពួក យើង នៅ ទី នេះ តើ អ្នក បង ភ្លេច យើង ហើយ ឬ ? »

5 លំអុត : បង្អោន ខ្លួន។
6 ហយានីក : កង ទ័ព សេះ។

# ស្តេច អន្ធរ

## ប្រលោមលោក

ប៉ុន្តែ ដំរី ខ្លះ ទៀត នៅ ពី លើ ខ្នង ពោពេញ ទៅ ដោយ បន្ទុក វាប់[7] នៃ គាររូប ជា ច្រើន ដូច្នេះ ពួក ខ្លួន មិន ហ៊ាន ឆ្លើយ តប អ្វីៗ ឡើយ ទៅ កាន់ ដំរី ព្រៃ ជា ប្អូន។ ក៏ ប៉ុន្តែ ដំរី អង្គរ ទាំងឡាយ ហាក់ ដូច ជា ធ្វើ ថ្លង់ ដើរ កាត់ របង ធម្មជាតិ ពីរ គឺ សម្លេង រអ៊ូរទាំ និង អនុស្សាវរីយ៍ ជា ច្រើន អនេក។

ដល់ វេន ពួក អ្នក, អូ! កូន ឥន្ទ្រី ដែល ជា វង្ស ព្រះ អាទិត្យ និង ឥន្ទ្រី ផ្សេងៗ ទៀត ជា ញាតិ នឹង គ្នា នាំ គ្នា ហោះ ហើរ លើ វេហា ជា ខ្សែ អរូបី ហើយ នាំ គ្នា ទៅ ប្រមូល ផ្តុំ ជា ហ្វូង អធិកអធម លើ ចុង ព្រឹក្សា នៃ ព្រៃស្បាត, នា ពេល នោះ ដែរ មាន រទះ សេះ បុរាណ សង់ ពី ឈើ មាន ខ្លិម ក្រអូប (ឈើ ចន្ទន៍) មាន ស្លាប ដ៏ ល្អ ឆើត ជិះ ដោយ ពួក ព្រះ ម្នាង ហោះ កាត់ ហ្វូង ឥន្ទ្រី។ អ្នក មេ នាង ទាំង នោះ ឈរ លើ រទះ សេះ, វាលៈ (សក់) សាត់ តាម វាយោ លើក ហត្ថា ដ៏ ទន់ភ្លន់ ទាញ បង្ហៀរ សេះ សម្បុរ ខ្មៅ និង ស ហើយ ស្រែក បញ្ជា ប្រកប ដោយ អំណាច នាយ ម្ចាស់ ដើម្បី បង្ហាញ ដល់ ពួក ឥន្ទ្រី នូវ អាវ ក្រោះ ពណ៌ ប្រាក់, ខែល ពណ៌ ក្រហម (ដូចល័ខ) ហើយ និង ឧមា (សន្តិភាព) ជា អធិធម្មជាតិ លើ ភក្ត្រា។ ស្ត្រីព្រហ្មចារី ស្រស់ ប៉ប្រិម ហោះ កាត់ ហ្វូង ឥន្ទ្រី ដែល ជា អ្នក ហុច មកុដ អោយ នាង ពាក់, មាន ក្អោក

[7] វាប់ : ធ្ងន់ ណាស់ ពិបាក នឹង សែង។

# ស្ដេច អន្ធរ

**ប្រលោមលោក**

ស្បែត ស្លាប នាង ដោយ ចំពុះ ដើម្បី សំអាត, មាន រ៉ូស៊្សីញ៉ុល បង្ហុយ គ្រឿង ក្រអូប លើ កាយ នាង ដូច អប់ ក្លិន សៅគន្ធ។ ឱ ! ព្រៃស្បាត ពិត ជា អាស្ថាន នៃ ម្រឹក  ជា ទី ឋាន ធ្វើ ឱ្យ និមិត្តរូប នៃ ភាព ប្រណីត និង អស្ចារ្យ នៃ ស្ត្រី ទាំងនោះ មាន តម្លៃ ជាង កន្លែង រស់នៅ របស់ មនុស្សលោក ទៅ ទៀត។

ដល់ វេន ពួក អ្នក ម្តង, អ្ហូ ! ខ្លារខិន ទាំងឡាយ នាំ គ្នា គ្រហឹម ប្រាប់ ថា អ្នក ជា បង ប្អូន ជីដូន មួយ នឹង ស្រី អប្សរា ចំនួន ប្រាំ រយ នាក់ របស់ ព្រះ រាជា, មើល ឃើញ កាយា របស់ ពួក នាង អន្ទែត ត្រសែត លេច ចេញ សុដន ពាក់ មកុដ មាស, សំពត់  ភ្នី មែក ឈើ កាន់ ទៀន អុច នៅ ពេល ថ្ងៃ ចែស ជិះ រទេះ ទឹម ដោយ ក្តាន់ ដូច ក្នុង សុបិន។ ទឹក មុខ របស់ នាង គ្មាន ចលនា ដូច គ្នា នឹង ពួក អ្នក ម្នាង។ ហើយ នាង ទាំងឡាយ នេះ ឯង ជា វាទិនី[8] ឬ ប្រកាសិកា អាទិ៍ របស់  ព្រះ រាជា។

ដល់ វេន ពួក អ្នក ម្តង, អ្ហូ ! ខ្លា ទាំងឡាយ នាំ គ្នា គ្រហឹម វចនៈ (ពាក្យ) ពិសិទ្ធ ឧម, នាំ គ្នា មើល តាមចន្លោះ នៃ ព្រឹក្សា ឃើញ ហត្ថី (ដំរីឈ្មោល) ខ្មៅ មួយ សែង បដិមា នៃ

[8] វាទនី : ស្ត្រី ជា អ្នក ពោល, ប្រកាសសិកា : ស្ត្រី ជា អ្នក ប្រកាសសេចក្តី។

# ស្តេច អន្ធរ

## ប្រលោមលោក

ទេវតា ដែល ជា រូបភាព នៃ ព្រះ រាជា។ ហើយ ខ្លា ទាំង នោះ នាំ គ្នា គ្រហឹម ព្រម គ្នា នូវ វជី[9] ពិសិទ្ធ ឧម។

សូម នៅ ស្ងាត់ស្ងៀម ! ដ្បិត ទេវតា បំបែក ព្រះ កាយ ព្រះ អង្គ និង ផែន ដី ជា បី រូប។ នៅ ពី ក្រោយ ដំរី ខ្មៅ ជា អ្នក សែង បដិមា នៃ ទេវតា, មាន ដំរី ស ដើរ ពី ក្រោយ ជា អ្នក សែង ត្រីមូរតី[10] របស់ ទេវតា។ សូម នៅ ស្ងាត់ស្ងៀម អ្នក ស្រុក ទាំង ពួង នៃ ព្រៃស្បាត !

គួរ នាំ គ្នា ប្រឹងប្រែង ចាប់ យក ឱ្យ បាន នូវ ចុណ្ណភាព (ភាពតូច) មួយ នៃ វិគ្គហ[11] របស់ ទេវតា, ជា ព្រះ ដែល បំបែក អង្គ របស់ ព្រះអង្គ ជា បី រូប កំពុង ដើរ ឆ្លង ព្រៃ នៃ វិជ័យបដាក, ផ្លិត ស្ពឹមស្លែ, ក្លស់ ច្រើន ជាន់, វត្ថៈ ស្តុតិ[12] និង វត្ថៈ បរិត្ត[13] ដែល ចង ភ្ជាប់ នៅ លើ ដង ដ៏ វែង មាន ដាំ ពេជ្យ និង មន្ត្រ ដែលយោល តាម វាយោ នៅ ជុំ វិញ ទេវតា ហើយ នាំ គ្នា ជ្រៀត ចូល រវាង ចន្លោះ ដួរ នៃ ព្រៃ ឯទៀតៗ។ ដូច្នេះ គួរ នាំ គ្នា ប្រឹងប្រែង ចាប់ យក ឱ្យ បាន នូវ ផ្នែក តូច មួយ នៃ វិគ្គហ របស់ ទេវតា ជា ព្រះ ដែល បំបែក អង្គ របស់ ព្រះអង្គ ជា បី រូប នោះ ដែល

---

9 វជី : ពាក្យសំដី។
10 ទ្រីមូរតី : Trinité.
11 វិគ្គហ : រូបរាង, ផ្នែកមួយ, ទម្រង់។
12 កំណាត់ ស្តុតិ : étoffe-louange.
13 កំណាត់ បរិត្ត : étoffe-prière.

# ស្ដេច អន្ធរ

**ប្រលោមលោក**

សណ្ឋិត មិន អាច ធ្លាក់ បាន លើ ខ្នង ដំរី តែ បែង ខ្លួន ព្រមគ្នា ជា បី សណ្ឋាន : ព្រះមហាក្សត្រ ផង ជា រាជ វធូ[14] ជា ទី ស្នេហា ផង និង ព្រះ ស្នំ កំណាន់ ផង។ ចូល នាំ គ្នា រំពៃ មើល ទស្សនីយភាព ដ៏ អស្ចារ្យ នេះ ចុះ អ្នក ស្រុក នៃ ព្រៃស្បាត អើយ !

តើ អ្នក ត្រូវ ស្រដី បែប ណា ទៅ បើ ប្រសិន ជា រវាំង លតា វា រលំ ហើយ ឃើញ ពួក អ្នក កំពុង បីតិ ចំពោះ ទេវតា យាង ចេញ ទៅ ជួប នឹង ទេវតា ?

ឃើញ វិញទៀត ពួក កញ្ញា លូន់[15] លេញ ចេញ សុដន មាន ទឹក មុខ ស្ងៀម ស្ងាត់ ; តែ មិន កាន់ ទៀនអុច និង ជិះ លើ រទះ ទឹម ដោយ ក្ដាន់, តែ ជា ក្រុម ដែល ម្នាក់ៗ កាត់ បទុមា (ផ្កាឈូក) ហើយ ដង ខ្លួន យោល នៅ លើ អង្រឹង ស្នែង។ គឺ ជា ពួក ក្រមុំសាវ[16] បី រយ នាក់ ជា ព្រះ ស្នំ នា ពេល អនាគត របស់ ព្រះ រាជា។ ដល់ វេន ពួក អ្នក ហើយ, ប្រភព នៃ ការ ថ្ងូរ, ដល់ វេន ពួក អ្នក ហើយ ពួក ទៀវ[17] ស្វែង រក អ្នក ណា ម្នាក់ ជា ទី ស្រឡាញ់។

ហើយ ភ្លាម នោះ ស្រាប់ តែ ព្រឹក្សា បាក់ រលំ ឮ ដូច សម្លេង សេះ ញី វិរាព (ស្រែក) វិរោជ: (កំហឹង), គោ រោទ៍, ខ្លា គ្រហឹម

---

1414 វធូ : ជាយា ដ៏ ក្មេង។

15 លូន់ : gracieux.

16 សាវ : ស្ត្រីក្រមុំ។

17 ទៀវ : ឈ្មោះ សត្វ ព្រាប មួយ ប្រភេទ។

# ស្តេច អង្គរ

## ប្រលោមលោក

- ដ្បិត នៅ ក្រោម ដំបូល មេឃ មាន ពួក ព្រះ អង្គ ម្ចាស់, ពាក់ មកុដ មាស មាន ស្នូង ស្រួច បី, សណ្ឋិត នៅ លើ ខ្នង ដំរី គ្រប ដោយ គ្រោះ ស្រោប មាស, ហើយ សម្លឹង ល្វឹម[18]។ នោះ ហើយ ជា សាហេតុ ដែល នាំ ឱ្យ ព្រឺក្បាល, អស់ សម្ដេច ទាំង ឡាយ នៃ រុក្ខា រោទ៍ ដូច រាជសីហ៍ និង គ្រហឹម ដូច ខ្លា រខិន និង ព្រួស ទឹក មាត់ ពណ៌ បៃតង ដូច នាគ។

ហើយ ភាព ស្ងៀមឈឹង ក៏ ត្រឡប់ មក វិញ នៅ លើ វេហា, នាំ ឱ្យ ឮ ដង្ហើម ធំ នៃ បុស្បា គួរ ឱ្យ មាន ការត្រេកត្រអាល។ ជា ថ្មី ម្ដង ទៀត ក្រុម អ្នក បិទ ក្បួន គឺ ដង្ហែ ដោយ កញ្ញា សោភ័ណ ប្រាំ រយ នាក់ បញ្ចេញ សុដន មាន ទឹក មុខ ស្ងៀម ស្ងាត់ ជិះ រទះ ទឹម ដោយ ក្ដាន់ ហើយ កាន់ ទៀន អុជ នៅ ពេល ថ្ងៃ ថែស, តាបស បី រយ នាក់ សម្រាន្ត ជា មួយ គាររូប លើ គ្រែស្នែង លើ ខ្នង ដំរី, និង ព្រះ ស្នំ ឯក, ពួក អមាត្យ និង យុទ្ធជន។

នេះ គឺ ជា ក្បួន ដង្ហែ « បង្ហាញ តូច » ដែល ជា ព្រះរាជហឫទ័យ នៃ ស្ដេច អង្គរ ទ្រង់ យាង ចេញ ប្រពាត រាជធានី តាម ដង វិថី នានា ទ្រង់ គង់ លើ រាជ ទីនាំង សាមញ្ញ, នេះ គឺ ជា ក្បួន ដង្ហែ ពាស មាស ដែល ស្ថិត នៅ ក្នុង ចក្ខុ នៃ មនុស្សលោក, នេះ ជា ហ្វូង នៃ ពួក ទេព្ដា ដែល មក ស្នំ វណិព្វក (យាចក) នៅ ឋាន វាឡម្រឹគ ក្នុង ព្រៃស្បាត,

[18] ល្វឹម ៈ ឆ្ងាយ រហូត មើល លែង ឃើញ។ A perte de vue.

# ស្តេច អន្ទរ

**ប្រលោមលោក**

នេះ គឺ ជា ទេវយាត្រា ដែល ទាញ យក ពី ព្រឹក្សា ម្រឹក បក្សា បក្សី នូវ អនុរវភាព លាក់ ខ្លួន នៅ ក្នុង បេះដូង ដុះដាល របស់ មនុស្សលោក។

# ស្ដេច អន្ធរ

## ប្រលោមលោក

# ភាគ ទី១

## ស្ដេច ឥសី

ប៉ុន្តែ នៅ ពេល នេះ ខ្ញុំ យក ដៃ អង្អែល សក់ ហើយ យក ចុង ដងប៉ាកកា ចង្អុល ឆ្ពោះ ទៅ រក ទេពធីតា ដែល ជា អ្នក អាច បំផុស នូវ គំនិត នៃ ភព អាស៊ី, ខ្ញុំ គូរ របង វេទមន្ត ជា វង់ នៅ ជុំ វិញ បបូរ មាត់ របស់ ពួក ព្រះ នាង ទាំង នោះ ហើយ សញ្ជឹង ដល់ ពួក អ្នក អាន នៅ មស្ជឹម ប្រទេស ព្រោះ ខ្ញុំ បារម្ភ ថា អ្នក ទាំងនោះ មិន បញ្ឈប់ ការអាន នៅ ត្រឹម តែ ក្បួន ដង្ហែ - លើ ពាក្យ អាស៊ី ដ៏ ពិបាក, លើ ដុំ ថ្ម ល្អិត នៃ ពាក្យ « យាចក »។ ដូច្នេះ ខ្ញុំ មិន បន្ត ទៅ ទៀត មុន នឹង យើង នាំ គ្នា ពន្យល់ ឱ្យ មាន វីមំសា[19] លើ ពាក្យ នេះ និង វិន័យ ផង ដែរ នៃ ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា ដែល ជា សាសនា មាន ឥទ្ធិពល លើ ស្ថាបត្យកម្ម នៃ នរភាវៈ របស់ ជនជាតិ អាស៊ី។ ប៉ុន្តែ ត្រូវ ធ្វើ ដូច ម្ដេច ទៅ ដើម្បី នឹង អាច យល់ ដឹង បាន បើ អ្នក និង សតិ របស់ អ្នក មិន ប្រឹងប្រែង ស្វែង រក អ្វីៗ ដែល មាន នៅ ក្នុង សតវត្ស ដើម របស់ មនុស្សជាតិ។ នៅ ក្នុង ចក្ក សម័យ ទំនើប របស់ ពួក មស្ជឹមជន អ្វី ដែល ជា លក្ខណៈ សម្បត្តិ របស់ ពួក ស្លូម គឺ នឹកប្រមាណ ថា ជា មនុស្ស កខ្វក់ គួរ ឱ្យ ខ្ពើម ព្រោះ មាន ដំបៅ ស្អុយ ពេញ ខ្លួន, ដូច្នោះ ទេ ឬ? ជា មនុស្ស កំ

---

[19] វីមំសា : ការពិចារណា ដោយ ល្អិត។

# ស្តេច អន្ធរ

**ប្រលោមលោក**

ជិល, អ្នក ឆបោក ប៉ិន ប្រសប់, មនុស្ស ឆ្កួត និង មហាតលិក[20], ដូច្នោះ ទេ ឬ ?។ តែ ក្នុង ករណី ណា មួយ ក៏ ដោយ គឺ ជា មនុស្ស ដែល មាន ក្លិន ស្អុយ បំផុត, មនុស្ស នៅ បាទ សង្គម, មនុស្ស មាន ឋានៈ ទាប ថោក។ នៅ អឺរ៉ុប តើ វា មាន ទំនាក់ទំនង អ្វី នឹង គ្នា រវាង ព្រះ មហាក្សត្រ និង អ្នក ស្នំ ទាន ? តែ ជួន កាល ជា ស្តេច ដែល កវី សរសេរ ប្រឌិត ឡើង ក្នុង គំនិត រវើរវាយ ជា ការ ផ្សងព្រេង ផុស ប្រាជ្ញា ក្នុង កវីនិពន្ធន៍ ដើម្បី សើច ចំអក លេង តែ គ្មាន អ្វី ជា មផ្សត នោះ ឡើយ។ តែ ថា នៅ អាស៊ី គឺ យើង ជួប ប្រទះ នឹង ស្តេច ជា ឆ្អឹង និង សាច់ ដែល ហុច ព្រះ ហស្ត ស្នំ ទាន។ ដូច្នេះ សុំ អ្នក ជឿ ខ្ញុំ ចុះ ព្រោះ វា ជា ការ ពិត នៃ អត្តភាព នេះ។ ហើយ មុន នឹង ចាប់ ផ្តើម បូរបាច់ប្រាប់ អំពី ធម្មជាតិ របស់ នរៈ នោះ, សូម អ្នកអាន ជា មស្នឹមជន ទាំងឡាយ គ្រាន់ តែ នាំ គ្នា ធ្វើ ដំណើរ តាម ផ្លូវ គំនិត ឆ្លង កាត់ លើ ជីវប្រវត្តិ ផ្ទាល់ របស់ អ្នក តែ ជា ដំណើរ បែរ ត្រឡប់ ថយ ក្រោយ ទៅ ក្នុង យុគ កណ្តាល។ ពេល នោះ វិសាលវិហារ របស់ អ្នក វា នឹង បំភ្លឺ នូវ ពាក្យ « យាចក » នេះ, ហើយ នុះន៎ ជា ពន្លឺ ដែល ខ្ញុំ នឹង យក មក បញ្ចាំង ទៅ លើ មហា បុរស របស់ ខ្ញុំ។ សូម រក្សា ទុក ក្នុង ចិត្ត នូវ ការនិទាន របស់ ខ្ញុំ នេះ ដែល ជា ពន្លឺ នៃ យុគ កណ្តាល។ គឺ ជា មធ្យោបាយ សំរាប់ យល់

[20] មហាតលិក : មន្ត្រី ក្នុង វាំង ដែល ត្រូវ គេ ក្រៀវ។ Eunuque.

ដឹង នូវ ការរចនា ជា ឧឡារិក ដ៏ឡូង ក្នុង ភាសា បារាំង ស្ដីពី គ្រប់ តួអង្គ នៅ អាស៊ី បូព៌ា។

ជា បឋម សូម ប្រញាប់ និយាយ អំពី យាចក, នរៈ នេះ នៅ សតវត្ស ទី ៩ ក្នុង ពុទ្ធសករាជ ដែល នៅ ក្នុង គតិ ធៀប នឹង សតវត្ស ទី ១២ នៃ គ្រិស្ដសករាជ, យាចក នោះ វា មិន មែន ជា មនុស្ស ស្មោកគ្រោក តែ ផ្ទុយ ទៅ វិញ ជា នរៈ ខ្លាំងក្លា និង ស្អាត - សំអាត ជើង ក្បាល ដោយ វិតិ និង ដោយ បព្វជ្ជា។ បុគ្គល នោះ មាន ក្លិន ក្រអូប មិន ដោយសារ អប់ សៅគន្ធ តែ ដោយសារ លាង ជំរះ កាយ បី ដង ក្នុង មួយ ថ្ងៃ នៅ ក្នុង ស្រះ ឈូក និង មាន សេវាលជាតិ ផ្សេងៗ ទៀត ដែល មាន ផ្កា ក្រអូប។ លើស ពី នេះ ទៀត, ជន នោះ មិន មែន ជា ចោរ ហើយ ក៏ មិន មែន ជា កុសីតបុគ្គ[21] ក៏ មិន មែន ជា អ្នក មាន គតិ សាមញ្ញ ក៏ មិន មែន ជា មហាតលិត។ ខ្ញុំ ក៏ មិន និយាយ ថា វា មិន មែន ជា ជន ដែល បាន រៀបរាប់ ទាំង នោះ ដែរ ដែល អ្នក នឹក ស្មាន តែ សូម អ្នក ទុក ជា គំនិត លលា របស់ ខ្ញុំ ទៅ ចុះ ថា យាចក ដែល ខ្ញុំ លើក មក និយាយា នោះ គាត់ មាន យាន ដង្ហើម នៃ ចង្វាក់ បេះដូង របស់ គាត់ គួរ ឱ្យ ឆ្ងល់ នៅ លើ លោក នេះ : ដ្បិត បេះដូង នៅ ក្នុង ដើមទ្រូង វា ដូច ជា ត្រចៀក ឬ សំបក ខ្យង បើ សិន ការធៀប នេះ ចំពោះ អ្នក វា ស្រួល យល់ ជាង, គឺ ជា សំបក ខ្យង ដែល មាន ស្នូរ សន្ទឹក លាន់

[21] កុសីតបុគ្គល : មនុស្ស ខ្ជិល។

# ស្ដេច អន្ធរ

### ប្រលោមលោក

ញ នូវ សេចក្ដីទុក្ខ ដែល ជា ការ បង្កើត ឡើង ទៅ ក្នុង ព្រលឹង។ លើស ពី នេះ ទៀត គឺ មិន មែន ជា អ្នកងារ, ស្ទួម នោះ គឺ ជា បុត្រា នៃ ព្រះមហាក្សត្រ - ដែល ភាព តុបតែង ខ្លួន វា លេច ចេញ ឯង ជា ធម្មជាតិ, ព្រោះ ព្រះអង្គ សម្អិតសម្អាង ជា ធម្ម ជាតិ ជា រាជវង្ស ដែល គេអាច ប្រណី បាន ព្រោះ សំអាង នៅ ក្នុង ងារ ជា សង្ឃ យាចក។ ជា ចំណាប់ អារម្មណ៍ នឹង ជាប់ ចិត្ត របស់ យើង សព្វ ថ្ងៃ នេះ នូវ អាការ មួយ ដែល វា ស្រដៀង គ្នា នឹង  ពួក ducs[22] នៃ មស្ឆិមប្រទេស គឺ ពណ៌ ក្រហម ជា និមិត្តរូ ប។ តែ រលា ក្បាល នៃ មហា បុរស របស់ ខ្ញុំ វិញ គឺ ជា ព្រះ អាទិត្យ សុទ្ធ សាត។ ចំពោះ នរៈ កោរសក់ នេះ គាត់ មាន ទស្សនៈ ថា មនុស្ស មាន គតិ លុះ ត្រា តែ បុគ្គល នោះ ជា បង ប្អូន នឹង សត្វ, រុក្ខជាតិ, ទេវតា, ហើយ ជីវិតសង្គម វា គ្មាន អ្វី នៅ ក្រៅ ពី ជីវិតសាសនា នោះឡើយ។

យាចក នោះ ចំពោះ ពួក ព្រាហ្មណ៍ ជា អច្ឆរិយៈជន ប្រកប ដោយ គុណវុឌ្ឍិ សំរាប់ បំពេញ មុខងារ ជា ព្រះមហាក្សត្រ - មិន តែ ដោយ សារ តែ ជា ព្រះ រាជបុត្រ របស់ ហ្លួង តែ ជា ព្រះ សង្ឃ យាចក យាង ចេញ ដើរទេស បិណ្ឌបាត តាម ផ្លូវ ទាំងឡាយ គ្រប់ លួក់ នៅ ក្នុង ព្រះ រាជ អាណាចក្រ។ ដែល ជា ស្ទួម ដែល

---

22 ជា ងារ នៃ ពួកអភិជន នៅ អឺរ៉ុប, ជា ព្រះ អង្គ ម្ចាស់ ក្នុង រាជវង្សានុវង្សនៅ ក្រៅ ពី ខ្សែ រាជវង្ស ដែល អាច ឡើង គ្រង រាជ សមបត្តិ បាន។ ពួក ព្រះ អង្គ ម្ចាស់ នោះ ច្រើន ជា ពូ មា អានុជ របស់ ព្រះ មហាក្សត្រ។

# ស្ដេច អង្គរ

## ប្រលោមលោក

ពួក សាសនាវិទូ ឆ្លាតវៃ នៅ អាស៊ី បូព៌ា - ដែល ជា ពួក អ្នក កសាង ប្រាង្គ ប្រាសាទ អង្គរ គ្មាន នរណា ទាស់ ចិត្ត នឹង គាត់ - ដែល ជា ស្ទួម អាច នឹង ប្រៀបធៀប នឹង ស្ដេច និង បព្វជ្ជា ឥត ខ្ចោះ - ទ្រព្យ នៅ លើ លោក នេះ ដែល ជា សម្បត្តិ របស់ មនុស្សលោក បាន ត្រូវ គាត់ បោះបង់ ចោល ទាំងអស់ ដោយ ចិត្ត ស្មោះ។ គឺ វា មក ពី ពួក អ្នក លេងសោច នាំ គ្នា បង្កើត[23] អាទិទេព ជា ល្បែង កាមរតី តែ តាម បាដិហារិយ៍ មិន បង្កើត សោះ នូវ មហន្តរាយ សាធារណៈ បែរ ជា នាំ មក នូវ សុភមង្គល ដល់ រាជនគរ ទៅ វិញ, ដូច ព្រះបាទ ឦសាណវរ័ន្ទ, ព្រះរាជា ថ្មី នៃ អង្គរ, មាន ព្រះ កាយ ដូច យក្ស, សាច់ដុំ ដូច ខ្លា ខិន មាន កំណើត ដើម្បី គ្រង រាជសម្បត្តិ។

ប៉ុន្តែ មុន នឹង ពិពណ៌នា អំពី លក្ខណៈ សម្បត្តិ នៃ មហា បុរស របស់ ខ្ញុំ, សូម អ្នក អាន ទាំង ឡាយ កំចាត់ ចោល នូវ ការ ភាន់ ច្រឡំ ដែល ជា ការ យល់ ឃើញ នៅ បស្ចិមប្រទេស ថា នានា អំបូរ នៃ មនុស្ស នៅ ឥណ្ឌូចិន មាន កំណើត ដើម តែ មួយ និង មាន អារិយធម៌ រួម គឺ ជាតិសាសន៍ និង អារិយធម៌ ចិន។

ត្រូវ ដឹង ថា ភាព ឧត្តុងឧត្ដម នៃ កម្ពុជា មិន មែន មាន ប្រភព ពី ចិន តែ ពី ឥណ្ឌា។ ប្រវត្តិសាស្ត្រ នៃ ទស្សនៈ នេះ គឺ ចាប់ ផ្ដើម ឡើង ពី សតវត្ស ទី១ នៃ គ្រិស្តសករាជ : ការ ចុះចត

---

[23] ពួក អ្នក លេង សោច បង្កើត : fabricateurs.

# ស្តេច អន្តរ

## ប្រលោមលោក

សំពៅ នៅ កម្ពុជា របស់ រាជវង្ស ឥណ្ឌូ មួយ អង្គ ជា ព្រះ អានុជ នៃ សោមសន្តតិវង្ស ដែល ព្រះ អង្គ នាំ មក ជា មួយ ព្រះ អង្គ នូវ អាទិទេព ទាំង ឡាយ និង អក្សរ។ គឺ ចាប់ ពី ពេល នោះ មក ដែល ស្តេច ទាំងឡាយ នៃ ទឹក ដី ចតុត្ថៈ (៣/៤) របស់ ឧបទ្វិប ជា ទៀបកោះ ឥណ្ឌូចិន ទទួល ឥទ្ធិពល ពី ឥណ្ឌា ត្រូវ បាន អាទិទេព នៃ ព្រហ្មញ្ញសាសនា ជា អ្នក ត្រួតត្រា ចិត្តគំនិត ហើយ បារគូ បុរោហិត នៃ វណ្ណៈ ព្រហ្មណៈ សំដែង គំនិត ស្តីពី ទេវភាព ជា ភាសា សំស្ក្រឹត នៅ លើ ទឹក ដី កម្ពុជា។

តែ ថា ពី បុព្វេ មួយ ពាន់ ឆ្នាំ បន្ទាប់ ពី ការហូរ ចូល នៃ កុលសម្ព័ន្ធ តូច មួយ របស់ ពួក អារ្យៈ មក ដល់ កម្ពុជា ហើយ ធ្វើ អភិគម ជា មួយ ខ្មែរ ជា អ្នក ស្រុក ដើម តែ បុព្វបុរស នៅ តែ និទាន នៅ ឡើយ អំពី មហា និរប្រវេសន៍ នៃ ពួក អ្នក ស្រុក ប៉េរាណេស (Bénarès) ដែល មាន រូបសម្បត្តិ ដូច ព្រះបាទ ឦសាណវរ័ន្ទ ជា បច្ឆាញាតិ នៃ រាជវង្ស របស់ ព្រះមហាក្សត្រ នៃ វង្ស ព្រាហ្មណ៍។ ព្រះ ភក្ត្រ របស់ ព្រះរាជា, កំពុង នៅ ក្នុង សុបិន, ស្ថិត នៅ ស្ងាត់ស្ងៀម, កំពុង ធ្វើ ពោធិសម្ភារ, ដែល ជា ភក្ត្រ បង្ហាញ ព្រម គ្នា នូវ គន្លង ចេញ ច្បាស់ ជា ប្រក្រតី ដូច ជា រូប ចម្លាក់ បែប ក្រិច-ពុទ្ធសាសនា[24], ដែល ជា ព្រះ ភក្ត្រ នៅ ក្នុង ស្ថានភាព នៃ ប្រពលភាព របស់ វិញ្ញាតិ ដ៏ ខ្ពង់ ខ្ពស់ បំផុត។ ប៉ុន្តែ បើ គេ ដោះ ចេញ កាឡៃមាស ដោយ ព្រះ អាទិត្យ នៃ ត្រូ

[24] ក្រិច-ពុទ្ធសាសនា : Gréco-bouddhique.

# ស្តេច អន្ធរ

**ប្រលោមលោក**

ពិក, ផ្សាផាត់ មុខ នៃ អារិយធម៌ ឥណ្ឌា នៅ ក្នុង ចិត្ត ពី ព្រះ ភក្ត្រ, ព្រះ ភក្ត្រ នោះ វា ដូច ជា ជនជាតិ ក្រិច តែ ម្តង។ គឺ ជា ចម្រៀង ថ្វាយ អាទិទេព ដ៏ ត្រេកត្រអាល ប្រកប ដោយ កាម គុណ ដែល ពួក ព្រាហ្មណ៍ រំឮក នៅឡើយ ដល់ បច្ឆាញាតិ នៃ បុព្វបុរស នៅ តំបន់ ឧត្តរ នៃ អឺរ៉ាស៊ី, និង បំណែក នៃ អំបូរ ពួក អារ្យ:, ដែល ស្ថិត នៅ មួយ ចំណែក នៅ ប្រទេស អ៊ីរ៉ង់ និង ទេសភូមិ រហោឋាន នៅ មស្ឋិមប្រទេស, មួយ ចំណែក ទៀត ស្ថិត នៅ តាម ដង ទន្លេ គង្គា (Gange) ដែល មាន អារិយធម៌ ចំណាស់ មក ហើយ, និង មក ដល់ កន្លែង រស់នៅ ជា ស្ថាពរ នៃ បុព្វបុរស នៅ មុខ មហា សមុទ្រ អូសេអានី, លើ ដី ជំរៀកឆ្នូត ខ្សែ តូច មួយ ដែល ទី កន្លែង ប្រជួប គ្នា ជា ជម្លោះ រវាង ស មុទ្រ ឥណ្ឌា និង មហា សមុទ្រ ប៉ាស៊ីហ្វិក។ ព្រះ ភក្ត្រ ដែល ពួក ជាងចម្លាក់ នៅ អង្គរ ឆ្លាក់ ជា អវតា នៃ ព្រះ ឥសូ វា ស្រដៀង នឹង ព្រះ Appolon នៅ ប្រទេស ក្រិច។ តែ ជា ព្រះ Appolon ផ្លាស់ថ្មី ដោយ មាន ការផ្សោប គ្នា រវាង អារិយធម៌ ឥណ្ឌា និង ទេពកោសល្យ ខ្មែរ, ព្រះ Appolon លើក តម្កើង អោយ ខ្ពស់ ដោយ បារមី នៃ ព្រឹក្សា នៅ ស្រុកខ្មែរ និង ព្រលឹង នៅ ក្នុង ប រិស្ថាន នៃ ហ្វូង នៃ ខ្លា ខ្លាខិន, ដោយ ភាព រុងរឿង នៃ មហា ស មុទ្រ ទាំង ពីរ, ដោយ ដំណើរ ញាប់ញ័រ នៃ ក្រុមផ្កាយ ទក្សិណ (Croix du sud), ដោយ សម្លេង រន្ទះ នៃ សវន្តី (ទន្លេ) ដែល មាន

# ស្ដេច អង្គរ

## ប្រលោមលោក

ប្រភព ពី បព្វត[25] ដ៏ បរិសុទ្ធ និង មាន កំពស់ ខ្ពស់ ជាង គេ, ទី បំផុត គឺ ព្រះ Appolon ផ្លាស់ រូបរាង ដោយ ជីវិត ក្នុង ចិត្ត, ប្រកប ដោយ បារមី ផុត ពី ខ្លួន ឯង ដោយ ស្ទឹងស្មាធិ, ដោយ សេចក្ដីស្រឡាញ់, ដោយ វិរសម្បត្តិ, ដោយ ឧមា។ បាទ ! ស្ដេច អង្គរ នោះ ព្រះអង្គ មាន ភាវរូប ដូច ព្រះ អាទិទេព របស់ ជន ជាតិ អាថែន (Athénien), តែ ព្រះ Phidias បើ ព្រះអង្គ ទត ឃើញ ស្ដេច អង្គរ ប្រហែល ជា ព្រះអង្គ បោះ កន្ត្រៃ របស់ ព្រះអង្គ ចោល នៅ ក្នុង និរាស ដោយ ព្រះអង្គ មិន អាច យល់ ដឹង បាន អំពី អាថ៌កំបាំង នៃ ព្រះភក្ត្រ របស់ ពោធិសត្វ ដែល បំភ្លឺ នៅ ឡើយ នូវ មហាសាគរ ឱ្យ ភ្លឺ ត្រចេះត្រចង់ ដែល ជា ឃ្លាំង នៃ ព្រះរាជទ្រព្យ សំរាប់ ថ្វាយ ដល់ ព្រះរាជា។ ដ្បិត នៅ សម័យ នោះ បុព្វបុរស មួយ ក្រុម តូច មួយ នៃ ពួក អារ្យ: នៅ ជា អ្នក ចែក ជាកេរ៍, នៅ ពេល ខ្លះៗ នៅ មាន ចែក នៅឡើយ នូវ ត្បូង មរកត ដ៏ វិចិត្រ ចាំង នៅ ក្នុង ត្របកភ្នែក នៃ ពួក បព្វជិត នៅ ស្រុកខ្មែរ។ ប៉ុន្ដែ បើ សិន ជា កែវ នេត្រា ធំ ទាំង ទ្វេ ពណ៌ បៃតង របស់ ព្រះអង្គ ហោះហើរ ទៅ ក្នុង ព្រៃស្បាត, បើ សិន ជា ទៅ ក្រាបពួន នៅ ក្នុង ដង្គុំ, បើ សិន ជា យក ប្រពលភាព នៃ អគ្គិ ខ្លួន ឯង ទៅ ក្រោប ផ្កាលា (អណ្ដាតភ្លើង) នៃ ព្រលឹង វា នឹង អាច មើល ឃើញ ដូច ភ្នែក ខ្លា។ ហើយ បើ សិន ជា រូប កាយ របស់ ព្រះអង្គ បង់ឃ្លាត បែក ពី ព្រលឹង វា ដូច ជា អន្ទង

---

[25] បព្វត : កន្សោមគាឌី, chaine de montagnes.

# ស្ដេច អន្ធរ

## ប្រលោមលោក

ហៅ ដោយ ភាពឯកោ នូវ រូបភាព នៃ ឆ្នាំព្រៃ ធ្លាក់ស្រយាវ មក ពី វិហារស៍។

ប៉ុន្តែ ព្រះកាយ របស់ ព្រះបាទ ឦសាណវរ័ន្ទ ចងសម្ព័ន្ធ នឹង ព្រលឹង ដោយ សក្ដិយស របស់ ព្រះមហាក្សត្រ, ដោយ សមាច័យ[26] នៃ ចំនួន បី ពាន់ បុព្វបុរស ក្នុង រាជ្យត្រកូល មក ក្រាប ពួន នៅ ក្នុង គ្រប់ ផ្នត់ តូច ធំ ក្នុង ព្រះកាយ, នៅ ក្នុង ទីកន្លែង ដ៏ សម្ងាត់ នៃ ព្រលឹង គឺ ធ្វើ ឱ្យ នរបតី ទទឹកជោគ នូវ បារមី តាំង ពី ព្រះបាទ ដល់ ព្រះសិរសា។ សូម្បី អ្នក ដែល ធ្លាប់ ស្គាល់ ព្រះអង្គ ច្បាស់ ក៏ មើល ឃើញ ដូច ជា ព្រះអង្គ កំពុង ស្ថិតស្ថាល ជា និច្ច ជា មួយ អាទិទេព។ ទោះ ជា ការញញឹម មាន ភាពផ្អែមល្ហែម របស់ ព្រះអង្គ តែ វត្តមាន បារមី របស់ ព្រះរាជា ពន្លឺយ នូវ ចេស្ដា ជា ឧឡារិក ហើយ ព្រះអង្គ, ខ្ញុំ និយាយ ម្ដង ទៀត ថា ទ្រង់ មាន កំណើត មាន ទម្រង់ ក្នុង តួ នាទី ជា ព្រះ មហាក្សត្រ ឥតខ្ចោះ : ទេវគុណ នូវ លក្ខណ: ជា អាទិទេព នៅ លើ ផែនដី។

ព្រះ រាជអាណាចក្រ របស់ ព្រះអង្គ មាន ទឹកដី ធំ ជាង ផ្ទៃដី នៃ អឺរ៉ុប ខាងលិច ដ្បិត បុព្វបុរស របស់ ព្រះអង្គ ដណ្ដើម ត្រួតត្រា ទឹកដី នៅ ខាង កើត ទល់ នឹង ព្រំដែន ឥណ្ឌា, ខាង ជើង ទល់ នឹង ដែនដី ដែល ចិន ដណ្ដើម យក បាន គឺ ដំបន់ តុងកឹង

[26] សមាច័យ : ការប្រមូលផ្ដុំ។

និង អណ្តាម ភាគ ខាង ជើង, ប៉ុន្តែ ពន្យឺត ទៅ ទិស និរតី តាម សមុទ្រ ឥណ្ឌា, រហូត ដល់ ខាង ត្បូង និង ខាង លិច តាម មហាសមុទ្រ ប៉ាស៊ីហ្វិក, ហើយ និង ក្រោបសង្កត់ ទឹកដី ឥណ្ឌូចិន ស្ទើរតែ ទាំង អស់, ឧបទ្វីប ម៉ាឡេស៊ី និង កោះ ជា ច្រើន។ ច្បាប់ នៃ រាជអាណាចក្រ នោះ ជា ច្បាប់ ដែល មហា សមុទ្រ ទាំង ពីរ ត្រូវ គោរព។ គឺ រាជនគរ នោះ ឯង ជា អ្នក បើក និង បិទ ទ្វារ ដ៏ សម្បើម និង ឧត្តម នៃ ទឹកដី បូព៌ា ដ៏ ចម្លែក និង បង្គួរ ភាព សម្បូណ៌ ដែល មិន ចេះ អស់ ពី មហាសាគរ ឆ្លោះ ទៅ អាទិទេព នៃ អង្គរ ប្តូរ នឹង មាស និង មនុស្ស រាប់ លាន នាក់ និង ដំរី ច្រើន រាប់ ក្បាល, ទេវតា, ទេពារក្ស និង ទេពអប្សរ រាប់ កោដិ អង្គ។

ព្រះអង្គ ជា អធិបតី នៃ ស្តេច បី រយ អង្គ, ជា បុរិន្ទ[27] ដាច់មុខ នៃ មនុស្ស បី រយ លាន នាក់ និង ចំនួន ឥត រាប់ បាន នៃ ព្រលឹង និង មច្ឆានព្វ និង ពិន្ទុង។ នៅ ស្រុក ខ្មែរ នៅ ពេល មាន សន្តិភាព, ព្រះអង្គ មាន ទាហាន ២ លាន នាក់, មាន សំពៅ ចម្បាំង ៥ ពាន់, មាន កងទ័ព សេះ មាន ចំនួន សេះ ៥ សែន ក្បាល, មាន ក្តាន់ ៥ សែន ក្បាល, មាន ដំរី ១ សែន ក្បាល ដោយ មិន ទាន់ រាប់ បញ្ចូល កងទ័ព ជើង គោក និង ជើង ទឹក

[27] បុរិន្ទ ៈ ម្ចាស់ស្រុក។

# ស្តេច អន្ទរ

## ប្រលោមលោក

របស់ ពួក នរបតី នៃ នគរ ចំណុះ ព្រះអង្គ ផង : ក្សត្រទ្រង់រាជ្យ ទាំង នោះ គឺ :

ព្រះមហាក្សត្រ នៃ នគរ សៀម,

ព្រះមហាក្សត្រ នៃ នគរ លាវ,

ព្រះមហាក្សត្រ នៃ នគរ ចំប៉ា,

ព្រះមហាក្សត្រ នៃ នគរ ភូមា,

និង នៅ ជុំវិញ នៃ ព្រះមហាក្សត្រ ទាំង នោះ មាន ប្រជារាស្ត្រ នៃ ដំរី។

ព្រះមហាក្សត្រ នៃ នគរ ស៊ូម៉ាត្រា,

ព្រះមហាក្សត្រ នៃ នគរ ជ្វា,

ព្រះមហាក្សត្រ នៃ នគរ បូណេអូ,

ព្រះមហាក្សត្រ នៃ នគរ បាលី,

ព្រះមហាក្សត្រ នៃ នគរ Prajna-Paramita,

ព្រះមហាក្សត្រ នៃ នគរ Sivapour,

ព្រះមហាក្សត្រ នៃ នគរ Vishnoupour,

ព្រះមហាក្សត្រ នៃ នគរ Cakyamounipour,

និង នៅ ជុំវិញ នៃ ព្រះមហាក្សត្រ ទាំង នោះ មាន មហា ពិន្ទង។

# ស្ដេច អង្គរ

## ប្រលោមលោក

បើ នោះ ជា មាន ប្រទេសរាជ ដី គោក និង សមុទ្រ ច្រើន ក្រៃ និង បិដូច ជា ក្រឡា ផ្ទៃដី នៃ ស្ដេច អង្គរ វា ធំ ទូលាយ ជាង ផែនដី នៃ សាកលលោក, វា ជ្រៅ ជាង មហាសាគរ, សមន្តរាជ នៅ លើ វិហា, អាទិទេព នៅ សុរាល័យ, នៅ ក្រោម ដី, ទេពារក្ស នៃ ប្រេតលោក, នាំ គ្នា មក នៅ ក្រាបទៀប ព្រះ បាទា របស់ ព្រះអធិបតី ជា ប្រក្រតី ដោយ ព្រះអង្គ មាន យោធិន ល្បីល្បាញ មាន ចោរជើងទឹក វិសារទ, ដោយ ឈ្នះ តាម ផ្លូវ ចិត្ត ពួក ព្រាហ្មណ៍។ ពួក អ្នក ទាំង នោះ បាន នាំ គ្នា បំពាក់ រាជរដ្ឋាភិបាល នៅ លើ សាកលលោក លើ ភារៈ នៃ ព្រះអធិបតី ជា ម្ចាស់ជីវិត របស់ ខ្លួន។ ដូច យ៉ាង ព្រះមហាក្សត្រ, របស់ អ្នក ត្រួសត្រាយ ដ៏ ក្រអឺតក្រទម នៅ បរលោក, ទទួល បាន បុព្វសិទ្ធិ តែងតាំង ពួក អាទិទេព និង ជ្រើសរើស ពួក ទេពារក្ស ; ព្រះអង្គ អាច គ្រាន់ តែ ប្រើ មេដៃ របស់ ព្រះអង្គ ដែល បាន ប្រសិទ្ធ ដោយ ពួក ព្រាហ្មណ៍ ធ្វើ ឱ្យ ពួក អាទិទេព ក្លាយ ជា ទេពារក្ស និង ទេពារក្ស ក្លាយ ជា អាទិទេព ; ព្រះអង្គ ទទួលបន្ទុក ផង ដែរ ជា អ្នក មាន សិទ្ធិ សម្បើម ធ្វើ មនុស្សលោក អោយ ប្រែប្រួល រូប ទៅ ជា ទេវតា ឬ អារក្ស។ ពួក ព្រាហ្មណ៍ បាន បូជា អំណាច ផ្តាច់ការ ដ៏ ទូលំទូលាយ ចំពោះ ព្រះអង្គ រហូត អាច ធ្វើ ឱ្យ ធម្មជាតិ បី យ៉ាង របស់ មនុស្ស ប្រែក្លាយ ជា ខ្មោច និង ទេវតា។ ហើយ ព្រះអង្គ ជា គ្រូហ្ម ចេះ គ្រប់ វិធី ប្ដូរ រូប វត្ថុ និង ផ្សំ ឱសថ

# ស្តេច អន្តរ

**ប្រលោមលោក**

គ្រប់ បែប យ៉ាង (alchimiste) នៅ លើ ដី មេ និង ក្នុង ឋាន ន រក។

ដូច្នោះ បន្ទុកជូន់ របស់ ព្រះអង្គ វា មិន ធូន់ ជាង ស្តេច នៅ អឺរ៉ុប, ដូច ជា saint Louis ព្រះអង្គ ស្លាយ បាប គ្រប់ បែប យ៉ាង របស់ ប្រទេស បារាំង, ព្រះអង្គ យក ទម្ងន់ នៃ ប្រជារាស្ត្រ និង នគាល័យ មក ដាក់ ក្នុង បន្ទុកជូន់ របស់ ព្រះអង្គ។ ទ្រង់ ទទួល បាន សុប្រភាព[28] គ្មាន ដែនកំណត់ ដូច គ្នា នឹង អំណាច របស់ Nabuchodonosor, វា, គ្មាន ខ្លាច នឹង ប្រែ ខ្លួន ជា វាឡម្រឹគ, វា ក៏ ជា អ្នក តាំងបង្កើត និង បំផ្លាញ វិញ ទេវតា។ ព្រះអង្គ វាយ ដណ្តើម យក បាន ទឹកដី ធំជេង ជាង ស្តេច Alexandre, ទ្រង់, គ្មាន បារម្ភ ពី មរណភាព ដែល អាច កែប្រែ តាម ចំណង់ចិត្ត ផែនទី នៃ ផ្ទៃមេឃ។

ដ្បិត ព្រះអង្គ មិនមែន ជា មនុស្ស ដូច ពួក ស្តេច នៅ អឺរ៉ុប ក៏ មិនមែន ជា អាទិទេព ខ្មោះ ដូច ពួក ស្តេច នៅ អាស៊ី។ ព្រះអង្គ មាន អាត្ម អរូបី ដែល ពួក បព្វជិត នាំ គ្នា យក លិង្គ ជា បដិភាព ជា វិមាន - គឺ គ្មាន អ្វី ក្រៅ ពី អាទិទេព។ ចុង នៃ លិង្គ នៅ ក្នុង ទេវភាព សុប្រកាស[29] គឺ គ្មាន អ្វី ក្រៅ ពី ព្រះភក្ត្រ របស់ ព្រះអង្គ នោះឡើយ។

---

[28] សុប្រភាព : អំណាចធំដុំ។
[29] សុប្រកាស : រុងរឿងចិញ្ចាច។

# ស្តេច អន្ទរ

## ប្រលោមលោក

ព្រះអង្គ មាន មាឌ ធំ ជាង មេឃ និង ដី។ តែ ព្រះអង្គ នេះ ឯង ដែល មាន ព្រះបន្ទូល ប្រើ សំដី ឆ្មើងឆ្មៃ ឆ្ពោះត្រង់ នភា[30]។ ព្រះអង្គ បញ្ជា ទៅ ព្រះ អាទិត្រ ថា :

- « រះឡើង, យើង បង្គាប់ ដល់ អ្នក » ព្រះអង្គ នេះ ឯង ដែល ត្រាស់បន្ទូល ទៅ កាន់ ព្រះ ចន្ទ ថា :
- « ព្រះអគ្គមហេសី និង មកុដ របស់ យើង ! » ហើយ ប្រជារាស្ត្រ ជឿជាក់ ថា ព្រះអង្គ អាច ប្រស់ មនុស្ស ស្លាប់ ហើយ ឱ្យ រស់ វិញ បាន។

គឺ នរេសួរ[31] នេះ ឯង ដែល ជា ក្សត្រទ្រង់រាជ្យ នៅ ស្រុកខ្មែរ ដ៏ ធំធេង។ ហើយ ពេល ដែល ព្រះអង្គ ចេញ បង្ហាញ ខ្លួន ព្រះអង្គ ឈរ លើ ដំរី ស ជា មេ ចំណាស់ ឱ្យ ប្រជារាស្ត្រ ឃើញ, ហើយ ប្រជារាស្ត្រ គោរព បូជា អាទិទេព តាម រយៈ ម្ចាស់ ជីវិត របស់ ខ្លួន គឺ ព្រះមហាក្សត្រ ហើយ ព្រះអង្គ មិន ដែល ខាន ត្រាស់ បន្ទូល រាល់ ពីរ ដង នៃ សតវត្ស ទៅ កាន់ ជំនិះ របស់ ព្រះអង្គ ថា :

« នៅ ពេល នោះ, យើង មាន សុបិន ឃើញ ព្រឹក្សា នៃ ព្រៃស្បាត, នឹងហើយ, ឯង និង អញ, ឱ ! ដំរី របស់ អញ, យើង មាន សុបិន ដូច គ្នា... »

---

[30] នភា : ពពក។

[31] នរេសួរ : អ្នក ដែល ជា ធំ ជាង អស់ មនុស្ស។

# ស្ដេច អន្ធរ

### ប្រលោមលោក

## ភាគ ទី២

ដ្បិតអី សតិ នៃ ព្រះមហាក្សត្រ, គួរនា[32] នឹង ដំរី របស់ ព្រះអង្គ, សតិ របស់ ហ្លួង ពោពេញ ទៅ ដោយ សេចក្ដីរីករាយ នៅ ម្ដុំ ព្រៃស្បាត។ នៅ ម្ដុំ នោះ ហើយ មិន នៅ ទី ណា ផ្សេង ទៀត ដែល ពួក ព្រាហ្មណ៍ នាំ គ្នា មក យាង ព្រះ យុវ័ន ដែលមាន ព្រះជន្ម ១៩ វស្សា ទៅ គ្រង រាជសម្បត្តិ នៅ ក្រុង កម្ពុជា និង លើ ឋាន ទេវតា, បាទ ! នៅ ម្ដុំ នោះ ហើយ, ហើយ មិន នៅ ទី ណា ផ្សេង ទៀត ឡើយ។

ព្រះមហាក្សត្រ ព្រះអង្គ ទម្លាប់ ត្រាស់បន្ទូល ស្រួសស្រែស ថា :

- យើង សុបិន ដូច ដំរី របស់ យើង។

ការណ៍ នេះ វា ជា ការពិត។ ព្រះអង្គ និង ដំរី របស់ ព្រះអង្គ មាន សុបិន នៅ ក្នុង ព្រៃស្បាត ហើយ ជួនកាល សុបិន ម្ដងម្នាក់។ សូម្បី ស្ថិត នៅ លើ បល្ល័ង្ក ឆ្ងាយ ពី ជំនិះ ថ្លៃ របស់ ព្រះអង្គ, ហ្លួង សុបិន យ៉ាងប្រពល ឃើញ តែ ដំរី របស់ ទ្រង់។

ព្រះអង្គ សុបិន ឃើញ ព្រឹក្សា, មនុស្សម្នា នៃ រុក្ខជាតិ ដែល នរូ មិន អាច នឹង មិន ទន់ចិត្ត បាន នៅ ចំពោះ មុខ ធម្មារណ៍ ក្នុង យល់សប្ដិ។ ព្រះអង្គ សុបិន ឃើញ ដើម ម៉ៃសាក់ ដូច ដើម ឥឡូវនេះ, ឃើញ ដំរី បុរាណ, ឃើញ សត្វ បុរាណ scralaos ផ្ដេក

[32] គួរនា : ដូច, ជា ពាក្យ ខ្ពស់ សំរាប់ ប្រើ នៅ ក្នុង អក្សរសិល្ប។

# ស្តេច អន្ធរ

**ប្រលោមលោក**

ខ្លួន ស្ទឹមស្ទែ នៅឡើយ នៅ ក្រោម ម្លប់ នៅ មុន ជំនាន់ ទឹកជំនន់ លិច ផែនដី ក្នុង សម័យ សត្វ បុរាណ brontosaures, ព្រះអង្គ សុបិន ឃើយ ដើម នាងនួន មាន ស្លឹក ពណ៌ ក្រហម លាតសន្ធឹង ដែល នាំ ឱ្យ បក្សា បក្សី ធំៗ គិត តែ ពី ទួញ នៅ ថ្ងៃ ទី ២ នៃ កំណើត លោកិយ, ព្រះអង្គ សុបិន ឃើង ដើម ពោធិ មាន លតា ជា សក់ វែង លាក់ បាំង នៅឡើយ ផ្កា អ័រគីដេ នៅ លើ ចុង ឈើ, សម្បុក របស់ បក្សី បុរាណ archéoptéryx ដែល ជា បុព្វបក្សី នៃ បក្សា, ព្រះអង្គ នៅ បន្ត សុបិន ឃើញ ព្រឹក្សា ផ្សេងទៀត ដែល កំពុង ស្វាប ដោយ នៅ រង់ចាំ ការមកដល់ របស់ ពួក ទេព្តា និង ការចាកចេញ របស់ ពួក ទេពារក្ស និង ព្រឹក្សាឯទៀត ស្វាបហួម ឮ សូរ សម្លេង ខ្លាំង ជាមួយ និង ទេពធីតា, និង ព្រឹក្សា ដទៃ គ្មាន ឈ្មោះ ពណ៌ ស ពិលាប មិន ចេះចប់ ពួនខ្លួន នៅ ត្រង់ កែង មែក មាន រោម ជា កែង ដៃ របស់ ស្លឹកឈើ ស្រពោន ដែល គ្មាន នរណា ដឹង ថា ជា ឋាន របស់ ត្រីមូរតី។ នៅ ក្រោម ការដកដង្ហើមធំ របៀង វា លាក់បាំង បឹង មួយដែល ប្រកប ដោយ អនុស្សាវរីយ៍ ដ៏ច្រើន នៃ ការពិសា ទឹករលក, ដែល ជា ទីស្ថាន មាន ការសង្ឃឹម ក្រៃពេក បញ្ចេញ កាំរស្មី របស់ ព្រលឹង, សុខសាន្ត, ហើយ ជា ទីកន្លែង សំរាប់ ចាក់ រូបភាព នៃ អ្នកពិឃាត អាទិទេព ចូល ទៅ ក្នុង ទឹកនឹង នៅក្រោម សម្លេង ស្រងេះស្រងោច ដ៏ រងំ នៃ ព្រឹក្សា ដែល មិន ឮការសោកស្តាយ របស់ វា, ដែល មិន ឃើញ ក្តីសង្ឃឹម របស់ វា, នៅ

# ស្ដេច អន្ធរ

**ប្រលោមលោក**

ទីកន្លែង នោះ ក៏ មាន ការលាក់បាំង វិហារ មួយ ពណ៌ រោហិត (ក្រហម) ព្យួរ នៅ លើ អាកាស ហើយ ប៉ោង ព័ទ្ធ ដោយ ព្រៃស្បាត គឺ ជា ឋាន និព្វាន។ បាទ ! ព្រះមហាក្សត្រ ក្នុង រហោ[33] នៃ ការ រង់ចាំ នៃ សង្ខតធម៌ (ការបង្កើត) នៃ ពពួក សត្វលោក ដោយ បារម្ភ ព្រោះ ឃ្លាំមើល តាំងពី រាប់ លាន ឆ្នាំ មកហើយ, ព្រះអង្គ បិទ ព្រះ នេត្រា គិតដល់, គ្មាន ធ្វើ អ្វី ផ្សេងទៀត នៅ ក្នុង ព្រៃ ស្បាត, នូវ ការវិលត្រឡប់ របស់ មហាព្រហ្ម[34] ដើម្បី ព្រះវិហារ មួយ ពណ៌ រោហិត ព្យួរ នៅ លើ អាកាស ហើយ ប៉ោង ព័ទ្ធ ដោយ ព្រៃ ស្បាត គឺ ជា ឋាន និព្វាន។

ហើយ ម្ដេច ក៏ ដូច្នេះ, ម្ដេច ក៏ ពណ៌ ក្រហម ? ព្រះមហាក្សត្រ មិន អាច មិន ដក ដង្ហើមធំ, ទ្រង់ នៅ ក្នុង ការស្រមៃ បពោសអង្អែល សារធាតុ នៃ រតនៈវត្ថុ[35] ស្រស់ ជា សំណង់ នៃ ព្រះវិហារ ដែល សង់ ពី ឈើ វិសិដ្ឋ ក្ដាំងងា ជា ឈើ ពណ៌ ក្រហម ពាស ទាំងស្រុង ពី មូលដ្ឋាន ដល់ កំពូល ដែល ជា សារធាតុ ផ្សំ ដោយ ធាតុ រួម នៃ រូបចម្លាក់ នៃ មនុស្ស, បរុសត្វ, អាទិទេព និង ទេពារក្ស - ដែល ព្រះរាជា ទ្រង់ ស្រមៃ - គឺ ចិពរ ដ៏ មហា ឆើតឆាយ។ ក៏ ប៉ុន្តែ ខ្ញុំ មើលឃើញ ព្រះវិហារ លូតចេញ បី ជាន់ ទៅ ខាងលើ ដែល ជា និមិត្តរូប នៃ ភវាភព (លោកា)។ ហើយ

---

[33] រហោ : ទីស្ងាត់។

[34] ព្រហ្មញ្ញ សាសនា មាន ប្រកាន់ ជំនឿ ថា មហាព្រហ្ម ជា អ្នកបង្កើត ពពួក សត្វលោក។

[35] រតនវត្ថុ : វត្ថុ ធម្មជាតិ ដ៏ប្រសើរវិសេស។

# ស្ដេច អន្ទរ

**ប្រលោមលោក**

មាន ចតុ ប្រាង្គ ជា មកុដ អណ្ដែត ព្រមគ្នា ទៅ លើ អាកាស ដាច់ ចេញ ពី សារធាតុ នៃ រតនៈវត្ថុ។ ដែល អស្ចារ្យ ដោយ ហួស ពី ការស្រមើស្រមៃ គឺ ស្ថិត នៅ ក្នុង ព្រៃស្បាត ដែល ព័ទ្ធ ឋាន និព្វាន ប្រគំ រងំ ដោយ សម្លេង រាបស្មើ នៃ ឃ្មោះ ស្រប នឹង ចង្វាក់ នៃ ទិវាចរ[36] នៃ បក្សា បក្សី និង សម្លេង ប៉ោង ស្រប នឹង ចង្វាក់ នៃ រត្តិចរ[37] នៃ បក្សា បក្សី ចំនួន ប្រាំ រយ ដែល ជា សាវ័ក របស់ ព្រះ សក្យមុនី។ ព្រះអង្គ នេះឯង កាល ទ្រង់ នៅ មាន ព្រះជន្ម ១៧ វស្សា ទ្រង់ គ្រាន់ តែ ជា ព្រះរាជបុត្រ នៃ ព្រះ មហាក្សត្រ ក្រុងកម្ពុជា នៅឡើយ, ព្រះអង្គម្ចាស់ ឰសាណវរ័ន្ទ, ធម្មនិដ្ឋ[38], ព្រះ ស្វាមី នៃ ស្ត្រី ព្រហ្មចារី របស់ ព្រះ ទាំង ទ្វេ មាន ព្រះនាម រួម ហៅ ថា ហរៈ-ហរិ[39], ទ្រង់ មក ពួន នៅ លើ លោក ដើម្បី ប្រតិបត្តិ ច្បាប់ មាណវិកា[40] ដែល ជា កាតព្វកិច្ច របស់ ព្រះអង្គ - ដូចគ្នា នឹង កាតព្វកិច្ច យោធា របស់ យុវជន នៅ ស្រុកបារាំង - ដែល បង្ខំ ព្រះអង្គ និង ក្មេងជំទង់ ដទៃទៀត ឱ្យ បួស សាមណេរ តាម ច្បាប់ សាសនា។ ហើយ ដូច្នេះ ឯង ដែល ក្មេងប្រុស នៅ ទី នោះ អាច ជ្រើសរើស អាវុធ របស់ ខ្លួន ដោយ គិត ទុក ជា មុន នៅ មុន ពេល គេ ហៅ ឈ្មោះ, ចំណែក ព្រះ

36 ទិវាចរ ៖ ដែល រកស៊ី តែ ថ្ងៃ។
37 រត្តិចរ ៖ ដែល រកស៊ី តែ យប់។
38 ធម្មនិដ្ឋ ៖ ដែលស៊ប់ក្នុងសាសនា។
39 ហរៈ ហរិ ៖ ព្រះសិវៈ និង ព្រះនារាយណ៍។
40 ច្បាប់ មាណវិកា ៖ ច្បាប់ សំរាប់ ប្រុស កំលោះ ត្រូវ គោរព ជា ចាំបាច់។

អង្គ វិញ ទទួល បាន បន្ថែម ទៀត នូវ បុញ្ញសិទ្ធិ ជា ប្រភាព (កម្លាំង) នៃ កងកិត្តិយស ដែល កើត មាន នៅ ក្នុង ចិត្ត សុទ្ធ ដែល នាំ ឱ្យ ទ្រង់ មាន ព្រះរាជហឫទ័យ រីករាយ។ នៅ ក្នុង កង នោះ ឯង ដែល មាន ពួក អាទិទេព, អារក្ស និង ទស្សនវិទូ ស្ម័គ្រចិត្ត ចូល បំរើ ដើម្បី ព្រះសម្ពុទ្ធ។ ព្រះ បិតា, ឥស្សរវ៉ែន, ភ្ញាក់ ផ្អើល ថា ជា ការអស្ចារ្យ ណាស់, ក៏ នាំ ឱ្យ ព្រះអង្គ ចេញទ្រង់ ព្រះ ផ្នួស នៅ វត្តអារាម សក្យមុនី ដែល ជា ទីស្ថាន របស់ ពួក អ្នក អទេវនិយម, យ៉ាងច្បាស់ ដ្បិត ព្រះសម្មាសម្ពុទ្ធ ជា ម្ចាស់ ព្រះអង្គ បដិសេធ អាទិទេព ហើយ ព្រះអង្គ, ឦសាណ, ទ្រង់ ដឹង ថា ទ្រង់ មិន ស្រូប យក ជា ដាច់ខាត នូវ ភាពអាទិទេព មក បញ្ចូល នៅ ក្នុង ព្រះ កាយ របស់ ព្រះអង្គ។

គឺ នៅ ត្រង់ លក្ខណៈ នេះ ហើយ ដែល ព្រះអង្គ ខុស ពី ទេវតា, នៅ មស្ទឹមប្រទេស រស់នៅ ទីប្រជុំ មនុស្ស ស្មើ នឹង ទេវភាព, ហត់នឿយ នូវ អត្ថិភាព ទិព្វ របស់ ខ្លួន ដើម្បី រក្សា ទុក នៅ ក្នុងកាយ ដោយ ភ័យ ខ្លាច បាត់បង់ កំណប់ទ្រព្យ នេះ។ តែ ចំពោះ ព្រះអង្គ ដែល ជា បច្ឆាញាតិ នៃ ពួក ព្រាហ្មណ៍ ទ្រង់ ផ្ទើ ផ្ទុយ ទៅ វិញ ព្រោះ ព្រះ កាយ របស់ ព្រះអង្គ ទទឹក ជោគ ដោយ ធាតុ អាទិទេព រួច ទៅហើយ ហើយ នៅ ពេល ដែល ទ្រង់ កំពុង យាត្រា លើ ពុទ្ធមាគ៌ា ក្នុង ព្រហាវ៍ន (ព្រៃ) ទ្រង់ គិត ដោយ រីករាយ ថា :

# ស្ដេច អន្ធរ

## ប្រលោមលោក

- នៅ ទី បញ្ចប់ អាត្មា អាច ស្ងប់ចិត្ត ចាកចេញ ពី អាទិទេព ទៅ ជ្រក នៅ ក្នុង វត្តអារាម របស់ ពួក អ្នក អទេវនិយម។

ព្រះអង្គ មិន ដែល ភ្លេច មួយ ថ្ងៃ សោះ អំពី ជីវិត របស់ ព្រះអង្គ ដែល ព្រលឹង មិន ដែល ខាន នៅ ក្នុង ភាវៈ « Bhakti »។ ដោយ មិន អាច រក ពាក្យ មាន អត្ថន័យ ដូច ពាក្យ សំស្ក្រឹត នេះ ដូច្នេះ គេ អាច ប្រើ ពាក្យ « communion[41] », ឬ « extase[42] », ឬ ក៏ «absorption de sa créature par Dieu[43] »។ តែ គ្មាន ការ បកប្រែ ណាមួយ អាច បង្ហាញ នូវ ពន្លឺឆ្លុះ របស់ ពាក្យ នេះ ហើយ ក៏ មិន អាច បង្ហាញ នូវ លក្ខខណ្ឌ ផ្ទៃក្នុង និង ពិស្ដា ដែល ចង្អុល បង្ហាញ ពាក្យ Bhakti នៅ ក្នុង ន័យ ពិត នៅ អាស៊ី នោះ ដែរ។ ប្រភព របស់ វា គឺ នៅ ឥណ្ឌា ដែល ជា ទីកន្លែង ផ្ដល់ នូវ ភាវៈ នៃ ព្រលឹង ដ៏ វិចិត្រ នៅ អាស៊ី។ ដូច្នេះ បើ យើង និយាយ ថា វា ជា សម្ពន្ធ ជាមួយ ភាពអាទិទេព ឬ Bhakti គឺ ជា គំនិត នៅ ក្នុង លក្ខខណ្ឌ ពិសេស របស់ ឥណ្ឌា។

គឺ មិន មែន នៅ ក្នុង ភាវៈ នៃ ការសោកស្ដាយ និង ការបារម្ភ និង សេចក្ដីគោរព ចំពោះ អាទិទេព ដែល ជា អ្នក មាន អំណាច កាត់ក្ដី, គឺ ឯកភាព នៃ គូសង្សារ រួម គ្នា តែ មួយ នៅ ក្នុង ហឫទ័យចិត្ត (សេចក្ដីរីករាយ), ត្រអេកត្រអាល, រំជួយចិត្ត,

---

[41] Communion : សមសន្ធា, ការត្រូវគំនិតគ្នា។

[42] Extase : បីតិ, សេចក្ដីត្រេកអរ, ព្រឺព្រួច។

[43] absorption de sa créature par Dieu : ការជ្រាបចូល ក្នុង ខ្លួន នូវ ធាតុ អាទិទេព។

ស្ងាត់ស្ងៀម និង មិន អាច សម្ដែង ដោយ វាចា បាន នៅ លើ ផែន អជម្មជាតិ។ អាទិទេព និង មនុស្ស គឺ តែ មួយ ; គូសង្សារ មិន ភ័យ ខ្លាច បាត់ គូស្នេហ៍ របស់ ខ្លួន និង ចាកចោល ខ្លួន។ ហើយ ដោយ ឧបហេតុ ដាច់ខាត នេះ - ព្រោះ ព្រះអង្គ គិត នៅ ក្នុង ភាពរន្ធត់ នៃ អាទិទេព : « មាស ស្នេហ៍ បង, អូន តាម បង ទៅ គ្រប់ ទីកន្លែង », មាណពន៍ ជា ព្រះ នេះ បាន ធ្លាក់ មក ក្នុង ឋាន នៃ ពួក អទេវនិយម។ ទាក់ទាញ ដោយ មនុស្ស ព្រាហ្មណ៍ បរិសុទ្ធ, ព្រះរាជា-បណ្ឌិត ដោយ ប្រសើរវិសេស, បុរស រៀបការ ជាមួយអាទិទេព មុន នឹង កើត ? ព្រះអង្គ ជា ការ កម្រមាន ដែល គេ ស្គាល់ ទ្រង់ ជា បុត្រា របស់ សិទ្ធាន្ត (គោល លទ្ធិ) នៃ ព្រះពុទ្ធ និង ទ្រឹស្ដី របស់ ព្រះអង្គ ជា ទីគោរព ដែល ជា អ្នក បតិដ្ឋាននិយម (positiviste) បារាំងសែស។ ប៉ុន្ដែ អវេទ និយម នៃ ពុទ្ធសាសនា វា មិន ដូច នឹង អវេទនិយម នៅ មស្ចឹមប្រទេស ដែល ជា ទ្រឹស្ដី គម្រាំង, ខ្វាក់ និង ថ្លង់, ជា ទ្រឹស្ដី បង្វែងដាន ពី អាទិទេព, បដិសេធ អត្តភាព នៃ ប្រតិសន្ធិ របស់ មនុស្ស បន្ទាប់ ពី ស្លាប់ ឬ ក៏ មិន រវល់ គិត ពី រឿង ហ្នឹង - ដូច ជា នៅ ក្នុង គតិ អឺរ៉ុប ដែល រិត ដោយ បដិក្ខិត[44] គ្រិស្ដ, ដែល កំទេច ដោយ ភាពអស្ចារ្យ នៃ អាទិទេព ដែល នាំ ឱ្យ មើល មិន ឃើញ នូវ អ្វី ដែល អាច យក វា មក ដាក់ ជំនួស បាន នឹង សុញ្ញភាព (néant)។ ប៉ុន្ដែ ព្រះពុទ្ធ ទ្រង់ ពិចារណា រហូត ដល់ ទី បញ្ចប់

---

[44] បដិក្ខិត : ដែល ធ្វើ ដោយ ឥត គិត។

# ស្តេច អន្ទរ

## ប្រលោមលោក

អំពី ទ្រឹស្តី នៃ អវេទនិយម របស់ ព្រះអង្គ ជាមួយ នឹង តក្កភាព[45] (logique) ដែល មាន អនុភាព, ឥតឈប់ឈរ និង មាន ភាពមុត ពិសេស : ព្រះពុទ្ធ មិនទុកខ្លួន ព្រះអង្គ ជា ព្រះ បង្កើត លោកា និង ជាមួយ ភ្នែកចិត្ត ទ្រង់ យល់ ឃើញ ថា គ្មាន នរណា អាច អោបក្រសោប បាន លោក អរូបិ ដ៏ វិសាល ទាំងឡាយ តាម ផ្លូវ វិញ្ញាណ, ព្រះអង្គ បង្ហាញ បន្ថែម អវេទនិយម របស់ ព្រះអង្គ រហូត ដល់ បរលោក និង ហួស ពី លោក នោះ ទៅ ទៀត។ ព្រះអង្គ ប្រកាស ថា : « វា គ្មាន អាទិទេព តែ មួយ, គ្មាន ថិរភាព, គ្មាន ព្រះ បង្កើត លោកា, មាន តែ ពហុ អាទិទេព ដែល មាន ជីវិត គ្មាន អមត ដូច មនុស្សលោក ដែរ, ហើយ នៅ លើ សុញ្ញភាព ដែល អ្វីៗ ដែល មាន កើត ឡើង នៅ លើ លោកិយ » ក៏ គ្មាន អមត ដែរ។ ដ្បិត នៅ អឺរ៉ុប, បន្ទាប់ ពី សុញ្ញភាព គឺ គ្មាន អ្វី ទៀត ទេ, ដូច្នោះ ទេ ឬ ? តែ នៅ អាស៊ី វិញ បន្ទាប់ ពី សុញ្ញភាព វា មាន ចិរភាព បើក ចំហរ។ គឺ ដោយ យល់ ច្រឡំ ទាំងស្រុង ទៅ លើ តម្លៃ នៃ ពាក្យ ឥណ្ឌា សុញ្ញភាព ដែល នាំ ឱ្យ មស្ចិមជន បកប្រែ ដោយ ធ្វើ ការវិនិច្ឆ័យ ជា មុន នៅ ក្នុង គំនិត សម្ភារនិយម ដែល នាំ ឱ្យ ជនជាតិ អឺរ៉ុប ជា ច្រើន ជឿ ជាក់ ថា អាច ប្រៀបធៀប ពាក្យ និពាន្វ នឹង សុញ្ញភាព។ ប៉ុន្តែ និពាន្វ វា ខុស ឆ្ងាយ ពី សុញ្ញភាព, និពាន្វ គឺ ជា ភាវៈ នៃ

---

[45] តក្កភាព (logique) ជា នាមសន្មត ដែល ខ្ញុំ បង្កើត ដើម្បី ស្រួល ប្រើ ក្នុង ប្រយោគ ជា ភាសា ខ្មែរ។ បើ មាន ការខុសឆ្គង សូម អក្សរសាស្រ្តវិទូ មេត្តា អភ័យទោស។

# ស្តេច អន្ទរ

**ប្រលោមលោក**

គតិបណ្ឌិត, បរមសុខ, អមត ដែល គ្រប់ សត្វលោក អាច ទៅ ដល់ បាន នៅ ក្នុង លក្ខខណ្ឌ ដែល ត្រូវ ឆ្លង កាត់ សុញ្ញភាព ជា មុន សិន ព្រោះ និពាន្ទ ស្ថិត នៅ បន្ទាប់ ពី សុញ្ញភាព គឺ ថា មិន នៅ ក្នុង សុញ្ញភាព នោះឡើយ។ ព្រះពុទ្ធ ទ្រង់ ត្រាស់បន្ទូល ថា : « នៅ លើ លោក នេះ គឺ ជា ទទេ តែ ប៉ុណ្ណោះ, នៅ លើ លោក នេះ គឺ ជា ការស្រមើស្រមៃ តែ ប៉ុណ្ណោះ » ប៉ុន្តែ ដើម្បី ស្ថាបនា នៅ លើ ទទេ និង នៅ លើ ការស្រមើស្រមៃ, នូវ លោកា របស់ ខ្លួន ផ្ទាល់, ការស្រមើស្រមៃ របស់ ខ្លួន ផ្ទាល់ ជា មួយ នឹង សម្ភារៈ របស់ ខ្លួន ផ្ទាល់, គឺ ត្រូវ ប្រើ សេចក្តីស្នេហា, សេចក្តីសប្បុរសទាន និង សេចក្តីមេត្តាករុណា។ រី ឯ ជីវិត វិញ, ជឿ ខ្ញុំ ចុះ, ព្រះពុទ្ធ ព្រះអង្គ មានការហត់នឿយ ច្រើន សតវត្ស ព្រោះ ទ្រង់ បាន រស់ នៅ ក្នុង ជីវិត ជា មនុស្ស ដែល ជា ការនឿយណាយ ផ្ទាល់ របស់ ព្រះអង្គ ច្រើនក្រៃ មិន ចេះ ចប់ នៅ ក្នុង អសក្កភាព[46] នឹង អាច បង្រួញ រយៈពេល រស់នៅ ដ៏ ខ្លី មួយ នៅ លើ ផែនដី, និង ពី មរណាភាព ទៅ សុញ្ញភាព ដូច ជនជាតិ អឺរ៉ុប ជា អ្នក អទេវនិយម។

ព្រះអង្គ, ជា គូសង្សារ របស់ អាទិទេព, នៅ លើ មាគ៌ា ដែល នាំ ព្រះអង្គ ទៅ កាន់ ទី វត្តអារាមទិព្វ, ទ្រង់ មាន ព្រះចិន្តា ថា

46 អសក្កភាព : ភាពប្រព្រឹត្តទៅមិនបាន។

# ស្ដេច អង្គរ

**ប្រលោមលោក**

« មក រក អាត្មា ចុះ, ឃាតករ នៃ គូស្នេហ៍ របស់ អាត្មា, ហើយ អាត្មា បើក ចំហរ ដៃ ទទួល អ្នក »។

តែ ព្រះអង្គ មិន មក ដល់ មុខ ទ្វារ នៃ ព្រះពុទ្ធ តែ ម្នាក់ ឯង ទេ គឺ មាន មនុស្ស ជា ក្រុម ហែ មក ជាមួយ។ ពួក ទាំង នោះ នាំ គ្នា ដើរ តាម ព្រះអង្គ ដូច ស្រមោល របស់ ព្រះអង្គ, អាទិទេព ជា អ្នក ណា ? ព្រះ ស្វាមី ជីវិន របស់ ព្រះ ទេវី ព្រះ នាម កាលី។ អាទិទេព ជា អ្នក ណា ? ដែល មាន អាយុ សមវ័យ នឹង ព្រះ អង្គម្ចាស់, ជា រាជវង្ស របស់ ពង្សាវលី បព្វជិត ដ៏ មាន រិទ្ធិ ដែល ប្រពៃណី នឹង បុព្វសិទ្ធិ របស់ ព្រះអង្គ ដែល ជា អ្នក ស្នង រាជ្យ បន្ត ដូច ទម្លាប់ នៃ សន្តតិវង្ស ព្រះមហាក្សត្រ នៃ អង្គរ, បើ សិន ជា មាន ព្រះរាជា ទើប តែ រលត់ ជីវិត, តែងតែ មាន ព្រះ រាជបុត្រច្បង ពី មួយ អង្គ ទៅ មួយ អង្គ ទៀត បន្ត រាជ្យ ដែល មាន ងារ ជា អាទិទេព គ្មាន នាម ត្រកូល, មាន តែ ឈ្មោះ ដើម អព្យាក្រិត, ឈ្មោះ ក្នុង ផ្លូវចិត្ត ហៅ ជា ការចំអក (sobriquet) និង ចំណុច សួរ, តើ វា គ្រប់គ្រាន់ ដើម្បី បង្កើត, បន្ត ដែល ធ្លាប់ មាន តាំង ពី មួយ ពាន់ ឆ្នាំ មកហើយ, នូវ មហិទ្ធានុភាព, ហេមៈ (មាស), អភិមានៈ របស់ គ្រួសារ ព្រាហ្មណ៍ ដំបូង បង្អស់ នៅ កម្ពុជា។

**នៅ មាន ត**